# សន្ធិសញ្ញា (Treaty)

សន្ធិសញ្ញា ត្រូវបានផ្តល់ន័យថា ជាកិច្ចព្រមព្រៀងលាយលក្ខអក្សរ រវាងរដ្ឋនិងរដ្ឋ រដ្ឋ និងអង្គការអន្តរជាតិ គ្រប់គ្រងដោយច្បាប់អន្តរជាតិ (សន្ធិសញ្ញា ស្តីពីច្បាប់ ស្តីពីសន្ធិសញ្ញា ឆ្នាំ ១៩៦៩)។ សន្ធិសញ្ញាមានច្រើនប្រភេទ (ពហុភាគី ឬទ្វេភាគី)។ វាអាចជាសន្ធិសញ្ញាមិនស្មើភាព។ វាជាប្រភពចម្បងនៃច្បាប់អន្តរជាតិ។ ឯកសារ ដែលត្រូវបានចាត់ថាជាសន្ធិសញ្ញា មិនអាស្រ័យទៅលើចំណងជើងទេ វាអាស្រ័យលើខ្លឹមសារនៃឯកសារ។

មានច្បាប់ ឬសន្ធិសញ្ញា ដែលចែងពីបុគ្គល ស្ថាប័ននិងសមត្ថកិច្ចក្នុងការចុះហត្ថលេខា ឬផ្តល់សច្ចាប័នលើសន្ធិសញ្ញា។ តាមសន្ធិសញ្ញា ឆ្នាំ ១៩៦៩ ប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាល រដ្ឋមន្ត្រីការបរទេស រដ្ឋទូត (Ambassador) (ជាមួយប្រទេសដែលស្ថានទូតតាំងនៅ) ឬ តំណាងរដ្ឋនៅអង្គការអន្តរជាតិ អាចចុះហត្ថលេខាលើសន្ធិសញ្ញ លើវិស័យខ្លួនទទួលបន្ទុក ដោយមិនទាមទារនូវលិខិតផ្ទេរសិទ្ធិទេ ដោយសារមានអំណាចហើយ (Full Power) ទេ។

នីតិវិធីនៃការអនុម័តសន្ធិសញ្ញា អាចមានតែមួយ ឬ រួមផ្សំ (single or composed procedure)។ សម្រាប់ Single Procedure ការចុះហត្ថលេខាបន្ទាប់ អាចបង្កើតជាចំណងកាតព្វកិច្ចដោយសន្ធិសញ្ញា។ Composed Procedure ការចុះហត្ថលេខាគ្រាន់តែជា ការកត់ត្រានូវការទទួលយកភាពដើមនៃខ្លឹមសារសន្ធិសញ្ញា។

សន្ធិសញ្ញាចូលជាធរមាន ជាទូទៅ ក្រោយរដ្ឋមួយចំនួន បានផ្តល់សច្ចាប័ន ឬ ទទួលយក (accession)។ ក្នុងករណីសន្ធិសញ្ញា មិនចែងពីពេលវេលាចូលជាធរមាន សន្ធិសញ្ញា ចូលជាធរមាន ក្រោយពីមានការព្រមព្រៀងពីរដ្ឋចរចាទាំងអស់ (Negotiating States)។ ក្រោយពីចូលជាធរមាន មាត្រា ១០២ នៃធម្មនុញ្ញអង្គការសហប្រជាជាតិ ទាមទារឲ្យមានការចុះបញ្ជីសន្ធិសញ្ញា (Treaty Registration)។

វិសាលភាពនៃកាតព្វកិច្ចក្នុងសន្ធិសញ្ញា អាស្រ័យទៅតាមការទទួលយករបស់រដ្ឋ។ រដ្ឋអាចចុះខរក្សាសិទ្ធិរក្សាសិទ្ធិមិនអនុវត្ត (Reservation) នៃមាត្រាណាមួយ (ទោះបីសន្ធិសញ្ញាមិនបានចែងអំពីការចុះខក្តី) កុំឲ្យតែផ្ទុយនឹងគោលបំណងនៃសន្ធិសញ្ញា។ រដ្ឋចុះខរក្សាសិទ្ធិនៅតែជាភាគី។ រដ្ឋជំទាស់នឹងខរក្សាសិទ្ធិ នឹងមិនចងកាតព្វកិច្ចដោយខនោះទេ។ ទីនោះ គេគួរធ្វើការបែងចែងរវាងខរក្សាសិទ្ធិ និងសេចក្តីថ្លែងការណ៍ (Declaration)។

សន្ធិសញ្ញា ថ្មីដែលមានកម្មវត្ថុ (object) ដូចសន្ធិសញ្ញាចាស់ នឹងចងកាតព្វកិច្ចដល់រដ្ឋនៃសន្ធិសញ្ញាចាស់ លើកលែងរដ្ឋនោះជំទាស់។ រដ្ឋអាចមិនគោរពតាមកាតព្វកិច្ច ក្នុងសន្ធិសញ្ញា ប្រសិនបើផ្ទុយនឹង កាតព្វកិច្ចក្រោមធម្មនុញ្ញអង្គការសហប្រជាជាតិ (មាត្រា ១០៣ នៃ ធម្មនុញ្ញ)។

សម្រាប់[វិធីសាស្ត្របកស្រាយ] រដ្ឋអាចយោងដល់មាត្រា៣១ នៃសន្ធិសញ្ញាឆ្នាំ ១៩៦៩ ដែលត្រូវបានចាត់ថាជា[វិធានទំនៀមទម្លាប់អន្តរជាតិ។] ជាដំបូង វាទាមទារនូវការពិនិត្យមើល ពាក្យពេចន៍ ក្នុងបរិបទតាមគោលបំណងនៃសន្ធិសញ្ញ។ បរិបទរួមមាន បុព្វកថា កិច្ចព្រមព្រៀងបន្ទាប់អនុម័តដោយរដ្ឋភាគី និងការអនុវត្តផ្សេងៗទៀតរបស់រដ្ឋ។ ជាចុងក្រោយ អ្នកបកស្រាយ អាចពិនិត្យមើល កំណត់ត្រាពិភាក្សារៀបចំសន្ធិសញ្ញា (travaux preparatoires) ដែលជាវិធីសាស្ត្របន្ទាប់បន្សំ។ ការបកស្រាយ ទាមទារនូវការបកស្រាយប្រកបដោយប្រសិទ្ធភាព (effective principle) ដោយសម្រេចតាមគោលបំណងនៃសន្ធិសញ្ញា។

សន្ធិសញ្ញា ត្រូវបានបញ្ចប់តាមកាលកំណត់ ឬរដ្ឋជាភាគីបានព្រមព្រៀងបញ្ចប់ (Termination)។ រដ្ឋក៏អាចដកខ្លួន ឬបដិសេធនូវសន្ធិសញ្ញាផងដែរ (Denunciation) (មាត្រា ៥៤ នៃសន្ធិសញ្ញាឆ្នាំ ១៩៦៩)។ ការបញ្ចប់ក៏កើតមានក្នុងពេលមានការផ្លាស់ប្តូរនៃស្ថានភាព (fundamental Change of Circumstances) នៅពេលសន្ធិសញ្ញាត្រូវបានអនុម័ត ឬទំនាស់នឹងវិធានខ្ពស់បំផុត ([*Jus Cogens*])។ សង្គ្រាម ក៏អាចនាំឲ្យមានការបញ្ចប់ ឬផ្អាកការអនុវត្តសន្ធិសញ្ញា ក្នុងករណីធ្ងន់ធ្ងរ។ ភាគី ត្រូវជូនដំណឹងដល់ភាគីផ្សេងអំពីការផ្អាក ដែលមានប្រសិទ្ធភាពក្រោយពេលភាគីម្ខាង ទទួលបានការជូនដំណឹង។ រដ្ឋក៏អាចជំទាស់នឹងការជូនដំណឹង។ រដ្ឋប្រើប្រាស់សិទ្ធិការពារខ្លួន (Self-Defense) មានសិទ្ធិផ្អាកការអនុវត្តសន្ធិសញ្ញា។ ក៏ប៉ុន្តែរដ្ឋដែលបំពាន (Aggressor) មិនអាចប្រើសិទ្ធិផ្អាកទេ សម្រាប់ប្រយោជន៍របស់ខ្លួន។ ដូចគ្នានេះដែរ រដ្ឋមិនអាចបញ្ចប់ ឬផ្អាកការអនុវត្តសន្ធិសញ្ញា មនុស្សធម៌ សិទ្ធិមនុស្ស ការការពារបរិស្ថាន ឬសន្ធិសញ្ញាពហុភាគីចែងបង្កើតច្បាប់ទេ (Multilateral law-making treaties) (Concise Encyclopedia of the United Nations, UNTS-United Nations Treaty Series, 2010, pp. 684-688)។